# ប្រតិទិននៃការដាំដុះដំណាំស្រូវ

## ឆ្នាំ: 




នៅពេលណា របៀបម៉េច និង អ្វីខ្លះដែលអ្នក អនុវត្តន៍ក្នុងការ គ្រប់គ្រងការដាំដុះ ស្រូវគឺជាគន្លឹះ សំរាប់ទទួលបាន **ជោគជ័យ!!**



| | | | | | |
|---|---|---|---|---|---|
| ឈ្មោះ: | | អាសយដ្ឋាន | | ទូរសព្ទ | |

គំរោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច(APPP/JICA)

# របៀបប្រើប្រាស់ ឬបំពេញប្រតិទិន "បើកចំហ"






សរសេរ "ឆ្នាំ"
ប្រសិនបើឆ្នាំ២០១៥
ឆ្នាំ: ២០១៥

ចូរបំពេញខែក្នុង
ប្រអប់ពេលអ្នកចាប់
ផ្តើមកត់ត្រា



សរសេរលេខថ្ងៃទី
ប្រសិនបើក្នុងខែមករា
ថ្ងៃត្រូវក្នុងខែមករា

# ជាដំបូង
# តើប្រតិទិននេះប្រើដើម្បីអ្វី?

- គោលបំណង: ដើម្បីបង្កើនប្រាក់ចំណូលសុទ្ធ (ប្រាក់ចំណេញ) ដោយការលុបបំបាត់នូវការខ្ជះខ្ជាយដែលត្រូវបានពិនិត្យ និងកត់សំគាល់តាមរយៈការកត់ត្រាការចំណាយចាំបាច់ជាច្រើន ដើម្បីទទួលបានប្រាក់ចំណូលសំរាប់អ្នក និងគ្រួសាររបស់អ្នក ប្រយោជន៍ក្នុងការដឹកនាំគ្រប់គ្រងជីវភាព និងធ្វើឲ្យជីវភាពកាន់តែប្រសើរឡើង។
- វិធីសាស្ត្រ: ដើម្បីគណនា និង វាយតម្លៃនូវភាពខុសគ្នារវាងការចំណាយចាំបាច់រាល់លើក/ប្រចាំថ្ងៃក្នុងការផលិតស្រូវរួមទាំងថ្លៃសម្ភារៈ ឧបករណ៍ ការគ្រប់គ្រងថែទាំ និងចំណាយផ្សេងៗទៀតជាដើម ហើយប្រាក់ចំណូលទទួលបានដោយការលក់ស្រូវ។ ចំណុចសំខាន់គឺថា បើអ្នកត្រូវស្វែងចេញឲ្យឃើញ ហើយកំណត់សំគាល់ និងអនុវត្តន៍នូវវិធីដែលធ្វើប្រសើរឡើង ដើម្បីគ្រប់គ្រងរាល់សកម្មភាពដាំដុះប្រចាំថ្ងៃរបស់អ្នក សំរាប់ឆ្នាំខាងមុខនាពេលអនាគត់ពីបទពិសោធន៍ផ្សេងៗដែលកើតមាននាពេលកន្លងមក ។

# របៀបក្នុងការកត់ត្រា(ឧទាហរណ៍ទី១)

- ការកត់ត្រាតាមស្រែ (ផែនការដាំដុះ)

| ស្រែ | ផ្ទៃដី(ហ.ត) | រដូវប្រាំង (ការដាំដុះលើកទី១) | | | រដូវវស្សា (ការដាំដុះលើកទី២) | | |
|---|---|---|---|---|---|---|---|
| | | ប្រភេទពូជ | វិធីសាស្ត្រដាំដុះ | ទិន្នផល (គ.ក) | ប្រភេទពូជ | វិធីសាស្ត្រដាំដុះ | ទិន្នផល (គ.ក) |
| ស្រែ ក | ០.៥ ហ.ត | អ៊ីអ៊ែរ ៦៦ | D.S. | ២០០០ | ផ្ការំដួល | N-T | ២៥០០ |
| ស្រែ ខ | ០.៧ ហ.ត | ជលសារ | D.S. | ២៥០០ | រាំងជ័យ | M-B | ២០០០ |
| ស្រែ គ | ០.២ ហ.ត | | | | ផ្ការំដួល | M-B | ១០០០ |
| សរុប | ១.៤ ហ.ត | | | ៤៥០០ គ.ក | | | ៥៥០០ គ.ក |

ចំណាំ: D.S.:ព្រោះដោយឧបករណ៍ត្រាំស៊ីឌ័រ, N-T: ស្ទូង, M-B: ព្រោះដោយដៃ

ប្រសិនបើអ្នកមានផ្ទៃដី៣កន្លែងនៅដាច់ៗពីគ្នា សូមសរសេរចូលក្នុងតារាងដូចដែលបានបង្ហាញ។ បន្ទាប់មកគិតពីផែនការដាំដុះដំណាំស្រូវ។ ទិន្នផលនឹងត្រូវបានកត់ត្រាជាចុងក្រោយបន្ទាប់ពីប្រមូលផលតាមស្រែនិមួយៗរួច។

